ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ជលផលកម្ពុជា

## (ដោយសង្ខេប)







ការបោះពុម្ពសៀវភៅនេះ ធ្វើឡើងក្រោមជំនួយរបស់សហភាពអឺរ៉ុប

# ជលផលកម្ពុជា

## (ដោយសង្ខេប)

ខ្លឹមសារនៅក្នុងសៀវភៅនេះជាការទទួលខុសត្រូវរបស់រដ្ឋបាលជលផលនិង
មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ។

ឆ្នាំ២០១៤
រដ្ឋបាលជលផល
អាគារលេខ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ កម្ពុជា ប្រអប់សំបុត្រលេខ ៥៨២

## អារម្ភកថា

ស្រូវនិងត្រីជាអាហារប្រចាំថ្ងៃយ៉ាងសំខាន់របស់ប្រជាពលរដ្ឋខ្មែរតាំងពីសម័យបុរាណមក ហើយត្រីមានសារៈសំខាន់ខ្លាំងណាស់មិនអាចកាត់ថ្លៃនិងពិព័ណ៌នាបានឡើយ។ ម៉្យាងវិញទៀត ប្រទេសកម្ពុជាសម្បូរទៅដោយធនធានធម្មជាតិគ្រប់ប្រភេទ ជាពិសេសធនធានជលផលដោយសារទីតាំងភូមិសាស្ត្រអំណោយផលគឺមានប្រព័ន្ធទន្លេមេគង្គជាង៥០០គីឡូម៉ែត្រនិងបឹងទន្លេសាបដែលជាបេះដូងនៃប្រទេស។

វិស័យជលផលបានរួមចំណែកយ៉ាងសំខាន់ក្នុងការផ្តល់ការងារដល់ប្រជាពលរដ្ឋប្រមាណ៦លាននាក់ ទាំងអ្នកធ្វើការពេញម៉ោងនិងមិនពេញម៉ោង បង្កើនជីវភាពរស់នៅ ផ្តល់នូវសន្តិសុខស្បៀងនិងបង្កើនផលិតផលក្នុងស្រុកប្រមាណ៨-១២% ដោយផលិតផលជលផលមានតម្លៃប្រមាណ១.៥០០លានដុល្លារសហរដ្ឋអាមេរិកក្នុង១ឆ្នាំ។

សព្វថ្ងៃនេះ ប្រទេសកម្ពុជាមានត្រីទឹកសាបប្រមាណ៥០០ប្រភេទនិងត្រីសមុទ្រ៥២០ប្រភេទ ហើយបរិមាណផលនេសាទសរុបប្រចាំឆ្នាំប្រមាណ៧០០-៨០០ពាន់តោនដែលជាប់ចំណាត់ថ្នាក់លេខ៤លើសកលលោក បន្ទាប់ពីប្រទេសចិន ឥណ្ឌា និងបង់ក្លាដែស។ ក្នុងនោះត្រីទឹកសាបប្រមាណ៥០០-៦០០ពាន់តោន សមុទ្រ១០០-១៥០ពាន់តោន និងវារីវប្បកម្ម៩០-១០០ពាន់តោន។ ដូចនេះ ប្រជាពលរដ្ឋខ្មែរម្នាក់គិតជាមធ្យមបរិភោគត្រី៦៣គីឡូក្រាមក្នុង១ឆ្នាំនិងទទួលបានប្រូតេអ៊ីនសាច់ពីត្រីចំនួន៨១,៥ %។

នាពេលបច្ចុប្បនេះ ប្រជាពលរដ្ឋមានការកើនឡើង ការប្រែប្រួលអាកាសធាតុ ការនេសាទហួសកម្រិត។ល។បានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើធនធានមច្ឆជាតិ ទើបរាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានធ្វើកំណែទម្រង់លើវិស័យជលផល ដោយលុបឡូត៍នេសាទទាំងអស់ទុកជូនប្រជាពលរដ្ឋគ្រប់គ្រងនិងប្រើប្រាស់ប្រកបដោយនិរន្តរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រនិងទុកមួយផ្នែកជាកន្លែងអភិរក្ស។

ចាប់តាំងពីកំណែទម្រង់គោលនយោបាយវិស័យជលផលពី២០០០ដល់២០១៤ គឺអស់រយៈពេល១៤ ឆ្នាំកន្លងមកហើយ រដ្ឋបាលជលផលបានខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការអនុវត្តតាមគោលនយោបាយកែទម្រង់ស៊ីជម្រៅនេះ រហូតសម្រេចបានជោគជ័យនិងទទួលបានសមិទ្ធផលយ៉ាងត្រចះត្រចង់ក្នុងនោះសមិទ្ធផលសំខាន់ៗរួមមានការអភិវឌ្ឍវារីវប្បកម្ម ការគ្រប់គ្រង និងអភិវឌ្ឍន៍សហគមន៍នេសាទ ការអភិរក្សធនធានជលផល ការកែលម្អនិងកំណត់ព្រំប្រទល់កន្លែងអភិរក្ស ការការពារព្រៃលិចទឹកនិងព្រៃកោងកាង ការអភិវឌ្ឍស្រះជម្រកត្រីសហគមន៍ ការកែច្នៃផលនេសាទនិងគុណភាព ការរៀបចំផែនការ ការសិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយ។

សាស្ត្រាចារ្យបណ្ឌិត **ណៅ ធួក**

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

# មាតិកា

ទស្សនវិស័យសម្រាប់រដ្ឋបាលជលផល..........-២-
បេសកកម្មវិស័យជលផល..........-២-
អាណត្តិនៃរដ្ឋបាលជលផល..........-២-
កំណែទម្រង់វិស័យជលផល(២០០០-២០១២)..........-២-
បរិមាណផលនេសាទពីឆ្នាំ(២០០០-២០១៣)..........-៣-
ការអភិវឌ្ឍវារីវប្បកម្មនិងស្រះជម្រកត្រីសហគមន៍..........-៤-
ការគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍នេសាទ..........-៥-
សកម្មភាពអភិរក្សជលផល..........-៧-
សកម្មភាពអនុវត្តច្បាប់..........-៩-
ការកែលម្អដែននេសាទនិងការការពារព្រៃលិចទឹក..........-១១-
សកម្មភាពការងារនិងសមិទ្ធផលផ្នែកកែច្នៃជលផល..........-១២-
ការសិក្សាស្រាវជ្រាវ..........-១៣-
វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលទឹកសាប..........-១៣-
មជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍវារីវប្បកម្មសមុទ្រ..........-១៤-
មជ្ឈមណ្ឌលផលិតត្រីពូជបាទី..........-១៥-
វិទ្យាស្ថានជាតិស្រាវជ្រាវនិងអភិវឌ្ឍន៍វារីវប្បកម្មសម្តេចតេជោ ហ៊ុន សែន.....-១៥-
កិច្ចសហប្រតិបត្តិជាមួយកម្មវិធីនិងគម្រោងនានា..........-១៥-
ការបោះពុម្ពផ្សព្វផ្សាយ..........-១៧-
រចនាសម្ព័ន្ធរបស់រដ្ឋបាលជលផល..........-១៨-
សន្និដ្ឋាន..........-១៩-

ម.ឯ.ឯ.ក AIDOC
Code: 147-033
Date:
Donated by:

## ទស្សនវិស័យសម្រាប់រដ្ឋបាលជលផល

គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានជលផលប្រកបដោយនិរន្តរភាព ដើម្បីរួមចំណែកធានាសន្តិសុខស្បៀង លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន ការរីកចម្រើននៃសេដ្ឋកិច្ចសង្គម និងការអភិវឌ្ឍប្រទេសជាតិ។

## បេសកកម្មវិស័យជលផល

- អភិរក្សធនធានជលផលនិងជីវចម្រុះប្រកបដោយនិរន្តរភាព ដើម្បីរួមចំណែកធានាសន្តិសុខស្បៀង លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន ការរីកចម្រើននៃសេដ្ឋកិច្ចសង្គមនិងការអភិវឌ្ឍប្រទេសជាតិ
- ធានាការគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព
- អភិវឌ្ឍវារីវប្បកម្មដើម្បីរួមចំណែកធានាសន្តិសុខស្បៀងនិងកាត់បន្ថយភាពក្រីក្រ
- ធានាគុណភាពនិងសុវត្ថិភាពផលផលិតផលជលផលនិង
- អភិវឌ្ឍនិងគ្រប់គ្រងខ្សែចង្វាក់ផលិតកម្មផលនិងផលិតផលជលផល។

## អាណត្តិនៃរដ្ឋបាលជលផល

- ការងាររដ្ឋបាលរួមមាន ការគ្រប់គ្រងរដ្ឋបាល ការចាត់ចែងរាល់សកម្មភាពជលផល និងអភិវឌ្ឍន៍សហគមន៍នេសាទ
- ការងារបច្ចេកទេសរួមមាន ការសិក្សាស្រាវជ្រាវវិទ្យាសាស្រ្ត អភិរក្ស អភិវឌ្ឍន៍ សេដ្ឋកិច្ចបច្ចេកវិទ្យាជលផល និងបច្ចេកវិទ្យាដែលពាក់ព័ន្ធនឹងជលផល ព្រមទាំងការបង្កើនវារីវប្បកម្មនិង
- ការងារអនុវត្តច្បាប់រួមមាន ការងារអធិការកិច្ច ការអង្កេត ការតាមដាន និងការត្រួតពិនិត្យរាល់សកម្មភាពជលផលក្នុងតួនាទីជាមន្ត្រីនគរបាលយុត្តិធម៌។

## កំណែទម្រង់វិស័យជលផល(២000-២០១២)

យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិឆ្នាំ២០១៤-២០១៨ និងក្របខណ្ឌផែនការយុទ្ធសាស្រ្តសម្រាប់វិស័យជលផលឆ្នាំ២០១០-២០១៩លើកស្ទួយផលិតផលជលផលដើម្បីបម្រើឲ្យការប្រើប្រាស់ក្នុងស្រុក និងទីផ្សារនាំចេញតាមរយៈ៖

- ការនេសាទត្រីធម្មជាតិទាំងសមុទ្រនិងទឹកសាប
- វារីវប្បកម្មសមុទ្រនិងទឹកសាប
- សម្របសម្រួលការកែច្នៃនិងការធ្វើពាណិជ្ជកម្ម។

តាំងពីឆ្នាំ២០០០ដល់២០១២ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើកំណែទម្រង់ស៊ីជម្រៅវិស័យជលផលដោយលុបឡូត៍នេសាទទាំងអស់ទុកជូនប្រជាពលរដ្ឋនេសាទលក្ខណៈគ្រួសារនិងកន្លែងអភិរក្សដែលមានដូចតារាងខាងក្រោម៖

| | ចំនួនឡូត៍ | ក្រឡាផ្ទៃ(ហ.ត) | ភាគរយ |
|---|---|---|---|
| កំណែទម្រង់លើកទី១(២០០០-២០១០) | ៧៨ | ៥៤១.២០៦ | ៥៦,៧៤ |
| កំណែទម្រង់លើកទី២(២០១២) | ៨០ | ៤១២.៥៣៤ | ៤៣,២៦ |
| កន្លែងអភិរក្ស | ៥០ | ៩៧.៥០៣ | ១០,២៣ |

បច្ចុប្បន្ននេះនៅព្រះរាជាណាចក្រកម្ពុជា ក្រៅពីឡូត៍នេសាទ នៅមានដាយត្រី ដាយបង្កង និងដាយត្រីលេញចំនួនទាំងអស់៩២ដាយ ក្នុងនោះដាយត្រីចំនួន៧១ដាយ ដាយបង្កងចំនួន១៣ដាយ និងដាយត្រីលេញចំនួន០៨ដាយ។ នៅរាជធានីភ្នំពេញមានដាយត្រីចំនួន២២ ដាយ ខេត្តកណ្តាលមានដាយត្រីចំនួន៤៩ដាយ និងដាយត្រីលេញចំនួន០១ដាយ ហើយខេត្តព្រៃវែងមានដាយបង្កងចំនួន១៣ដាយ និងដាយត្រីលេញចំនួន០៧ដាយ។

រាជរដ្ឋាភិបាលរក្សាទុកដាយត្រីទាំងអស់នេះ សម្រាប់ផ្គត់ផ្គង់ត្រីប្រហុក ផ្អកដល់ប្រជាពលរដ្ឋ នៅក្នុងតំបន់ឬបណ្តាខេត្តជិតឆ្ងាយ ពីព្រោះវាជាអាហារមិនអាចខ្វះបានរបស់ប្រជាពលរដ្ឋខ្មែរ។ ដាយទាំងអស់នេះត្រូវបានដាក់ដេញថ្លៃជាសាធារណៈរៀងរាល់០២ឆ្នាំម្តង។





## បរិមាណផលនេសាទពីឆ្នាំ(២០០០-២០១៣)




នៅក្នុងរយៈពេល១៤ឆ្នាំនេះ បរិមាណផលនេសាទសរុបមានការកើនឡើង ហើយក្នុងនោះ បរិមាណផលនេសាទទឹកសាបខ្ពស់ជាងបរិមាណផលនេសាទសមុទ្រ តែមានការប្រែប្រួលតិចតួច និងមានការអភិវឌ្ឍវារីវប្បកម្មកើនឡើង។ ប្រជាពលរដ្ឋខ្មែរម្នាក់ៗគិតជាមធ្យមបរិភោគត្រី៦៣ គីឡូក្រាមក្នុងមួយឆ្នាំ ក្នុងនោះប្រភេទត្រីទឹកសាប៤៤,២ គីឡូក្រាម ប្រភេទត្រីទឹកសមុទ្រ១៧,៣ គីឡូក្រាម និងប្រភេទត្រីចិញ្ចឹម១,៣គីឡូក្រាម ហើយទទួលបានប្រូតេអ៊ីនសាច់ពីត្រីរហូតដល់៨១,៥ ភាគរយ។ ជាបរិមាណត្រីកែច្នៃជាក់ស្តែង ប្រជាពលរដ្ឋខ្មែរម្នាក់បរិភោគប្រហុក៥,២គីឡូក្រាម ផ្អកឬមាំ៤,៨គីឡូក្រាម ត្រីឆ្អើរ៨,៣ គីឡូក្រាម ត្រីងៀត៩,៣ គីឡូក្រាម និងទឹកត្រី៤,៥ លីត្រ។





## ការអភិវឌ្ឍវារីវប្បកម្មនិងស្រះជម្រកត្រីសហគមន៍

នៅពេលបច្ចុប្បន្ននេះ ប្រជាពលរដ្ឋខ្មែរមានការយល់ដឹងនិងផ្លាស់ប្តូរទម្លាប់ពីការពឹងផ្អែកលើត្រីនៅក្នុងបឹងធម្មជាតិមកការចិញ្ចឹមត្រីវិញ ដូចនេះការចិញ្ចឹមត្រីមានការរីកចម្រើនផុលផុសគួរឲ្យកត់សម្គាល់ ក្នុងនោះបរិមាណផលិតកូនត្រីពូជ ចំនួនកសិដ្ឋានផលិតកូនត្រីពូជ ចំនួនសហគមន៍ស្រះជម្រកត្រីមានការកើនឡើងពី១ឆ្នាំទៅ១ឆ្នាំ។

ស្រះជម្រកត្រីជាប្រភេទតំបន់ការពារឬអភិរក្សត្រី ជាទូទៅត្រូវបានបង្កើតឡើងនៅតាមតំបន់ទំនាបវាលស្រែដែលលិចទឹកនៅរដូវវស្សា ឆ្ងាយពីតំបន់មជ្ឈដ្ឋានទឹកធម្មជាតិដែលមានទឹកពេញមួយរដូវ។ សារៈប្រយោជន៍នៃស្រះជម្រកត្រី គឺចូលរួមចំណែកដ៏ធំធេងក្នុងការបង្កើនធនធានជលផលនិងផលនេសាទនៅតាមតំបន់ទំនាបវាលស្រែ។ បច្ចុប្បន្ន ស្រះជម្រកត្រីត្រូវបានបង្កើតបានចំនួនសរុប៨២០កន្លែងដែលផែនការបន្តទៀតនិងរៀបចំឲ្យបានយ៉ាងតិច១ស្រះក្នុង១ឃុំទូទាំងប្រទេស។




ប្រជាពលរដ្ឋប្រមាណ៦៣.០០០គ្រួសារបានចូលរួមនៅក្នុងសកម្មភាពចិញ្ចឹមត្រីដែលបានទទួលការបណ្តុះបណ្តាលបច្ចេកទេសពីរដ្ឋបាលជលផល ក្នុងនោះមានកសិករ១៥៤នាក់ជាគ្រូបង្គោលនិងជាគ្រូផ្សព្វផ្សាយនៅតាមមូលដ្ឋាន។ ប្រភេទត្រីចិញ្ចឹមរួមមាន ត្រីស្លង់ ត្រី-តុកកែ ក្រែងឈាម ត្រីឆ្ពិន ត្រី កាហែ ត្រីប្រាធំ ត្រីក្រាញ់ ត្រីអណ្តែងកូនកាត់ ត្រីខ្យា ត្រីព្រលូង ត្រីកន្ធរ ត្រីទីឡាព្យ៉ា ត្រីកាបស ត្រីកាបសាមញ្ញ អន្ទង់ និងបង្កងទៀតផង។ នាពេលបច្ចុប្បន្ននេះ បរិមាណផលវារីវប្បកម្មមានចំនួន៩០. ០០០តោន ស្មើ១២%នៃបរិមាណផលត្រីសរុបដែលក្នុងនោះមានវារីវប្បកម្មទឹកសាប៩០% និងសមុទ្រ១០%។

| ចំនួនកន្លែងភ្ញាស់ត្រីនិងស្រះជម្រកត្រីសហគមន៍(ឆ្នាំ២០០០ទៅដល់ឆ្នាំ២០១៣) | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ក. | ៥ | ៦ | ១៤ | ៣៦ | ៤៨ | ៦៣ | ៦៩ | ៨៣ | ១៤៥ | ១៩៥ | ២៧៣ | ២៨០ | ២៩៦ | ៣០៧ |
| ខ. | ២ | ៣ | ៨ | ១៥ | ២២ | ២៩ | ៣៦ | ៤៩ | ១៦៣ | ៣១៧ | ៦៥៤ | ៧៣៨ | ៧៦៤ | ៨២០ |
| | ក.ចំនួនកសិដ្ឋានផលិតកូនត្រីពូជ ខ.ចំនួនសហគមន៍ស្រះជម្រកត្រី | | | | | | | | | | | | | |

សមិទ្ធផលសំខាន់ៗដែលសម្រេចបានរួមមានៈ

១. បានរៀបចំបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងដំណើរការរៀបចំនិងគ្រប់គ្រងសហគមន៍នេសាទ។

២. រៀបចំសហគមន៍នេសាទបានចំនួន៥១៦សហគមន៍ ដែលមានសមាជិកសរុបចំនួន៣៣២.១៦៨នាក់ (ប្រមាណជាង៣៥% ជាស្ត្រី) ត្រូវជា១៤៧.៥១៨ គ្រួសារ ក្នុងនោះសហគមន៍នេសាទដែលមានទីតាំងនៅក្នុងដែននេសាទទឹកសាបមានចំនួន៤៧៧និងតំបន់ឆ្នេរមានចំនួន៣៩សហគមន៍។ សហគមន៍នេសាទចំនួន៣៧០ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ចំពោះសហគមន៍នេសាទនៅសល់ផ្សេងទៀត រដ្ឋបាលជលផលកំពុងរៀបចំឯកសារពាក់ព័ន្ធ ដើម្បីបញ្ជូនទៅក្រសួកងសិកម្ម រុក្ខាប្រមាញ់ និងនេសាទសុំចុះបញ្ជីជាបន្តបន្ទាប់ទៀត។

៣. បើកវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលាបានចំនួន៨២៨វគ្គ ដែលមានអ្នកចូលរួមចំនួន២៥.៦២២នាក់ (ប្រមាណជាង៤០%ជាស្ត្រី)។

៤. ផ្សព្វផ្សាយបានចំនួន៧៦៩ វគ្គ ដែលមានអ្នកចូលរួមចំនួន១០៩.៩៤១នាក់ (ប្រមាណជាង ៥០% ជាស្ត្រី)។

៥. រៀបចំទស្សនកិច្ចសិក្សាបានចំនួន៧៥លើក ដែលមានអ្នកចូលរួមចំនួន១.៦៧២នាក់ (ប្រមាណជាង៣៥%ជាស្ត្រី)។

៦. បោះបង្គោលព្រំប្រទល់កន្លែងនេសាទសហគមន៍បានចំនួន៥.៦៣៣ និងស្លាកសញ្ញាចំនួន ៤២៦ស្លាក។

៧. រៀបចំធនាគារក្តាមបានចំនួន៣២កន្លែងស្មើនឹង៩៥ បែ ដែលបានលែងមេក្តាមចូលចំនួន ៣៥.៧៦៣គីឡូក្រាមស្មើនឹង២៥៩.៤៩៨ក្បាល ដែលបានបញ្ចេញកូនក្តាមប្រមាណ ៣៦៦ ពាន់លានក្បាលទៅក្នុងដែននេសាទវិញ ហើយផលក្តាមបានកើនឡើងចំនួន៤ដង។

៨. អនុវត្តជម្រើសមុខរបរចិញ្ចឹមជីវិតដោយសហគមន៍នេសាទរួមមាន ការធ្វើអាងភ្ញាស់ ការចិញ្ចឹមត្រី ការដាក់របាំងផ្ទស់ចាប់ត្រី ដាយត្រី ការចិញ្ចឹមជន្លេន ការដាំបន្លែ និងបណ្តុះផ្សិត ការកែច្នៃផលនេសាទដែលមានស្ត្រីចូលរួមយ៉ាងសកម្ម។ ជាមួយគ្នានេះ សហគមន៍នេសាទបានទទួលកម្មវិធីឥណទានខ្នាតតូចពីគម្រោងជួយខ្លួនឯង(ទុនសន្សំពីសមាជិក)សប្បុរសជននិងអង្គការនានាផងដែរ។ បច្ចុប្បន្ននេះ សហគមន៍នេសាទមួយចំនួនមានប្រាក់សន្សំ

ក្នុងសហគមន៍នេសាទរបស់ខ្លួនរហូតដល់ជាង១០០លានរៀល សម្រាប់ជាទុនបង្វិលជួយដល់មុខរបរចិញ្ចឹមជីវិតរបស់សមាជិក។ តាមរបាយការណ៍វាយតម្លៃសហគមន៍នេសាទនៅទូទាំងប្រទេសដែលបានចេញផ្សាយនៅឆ្នាំ២០១៣ ដោយរដ្ឋបាលជលផលដែលបានសម្ភាសជាមួយសមាជិកចំនួន១០៩៥នាក់ និងពិភាក្សាជាក្រុមចំនួន១២០ក្រុម (៦០ ក្រុមជាស្ត្រី) នៃសហគមន៍ចំនួន៦០ដែលបានជ្រើសរើសបានបង្ហាញថាក្រោយកំណែទម្រង់វិស័យជលផល៖

ក. ចំនួនអ្នកពាក់ព័ន្ធនឹងការងារនេសាទកើនឡើង ជួយប្រជាពលរដ្ឋក្រីក្រចាប់បានត្រីច្រើនជាងមុននិងរកចំណូលបានច្រើនពីនេសាទ (៨៥%នៃសមាជិកដែលបានសម្ភាស)។

ខ. តាមរយៈសហគមន៍នេសាទជួយឲ្យពួកគាត់មានទំនុកចិត្ត ជឿជាក់ ឯកភាពគ្នា និងមានកិច្ចសហការល្អប្រសើរលើគ្រប់វិស័យពីគ្រប់មជ្ឈដ្ឋានទាំងក្នុងនិងក្រៅភូមិ ដែលមុខងារនេះដើរតួនាទីយ៉ាងសំខាន់បំផុត គឺប្រហែលជាមានសារៈសំខាន់ជាងការចាប់ត្រីទៅទៀត (៩៥%នៃក្រុមពិភាក្សា)។

គ. សមាជិកសហគមន៍នេសាទប្រមាណជាង៦៣% មានការយល់ដឹងច្រើនពីតួនាទីភារកិច្ចរបស់ខ្លួន ជាពិសេសយល់ដឹងពីសារៈសំខាន់នៃការចូលរួមគ្រប់គ្រងនិងអភិរក្សធនធានជលផលឲ្យមានប្រសិទ្ធភាពនិងនិរន្តរភាព។

៩. សហគមន៍នេសាទចំនួន២៨បានប្រកាសខ្លួនជាសហគមន៍នេសាទគ្មានបទល្មើសក្នុងនោះនៅខេត្តកំពង់ឆ្នាំងមានចំនួន៤សហគមន៍។



កន្លែងអភិរក្សជលផលដែលមានការគ្រប់គ្រងត្រឹមត្រូវ ជាពិសេសមានការល្បាតជាប្រចាំ និងការចូលរួមគ្រប់គ្រងពីសហគមន៍នេសាទ កន្លែងនោះមានការកើនឡើងនូវផលស្តុកប្រមាណ ១៥% ជារៀងរាល់ឆ្នាំ បទល្មើសមានការថយចុះប្រមាណ៨៥% ហើយប្រជានេសាទដែលបានទទួលវគ្គបណ្តុះបណ្តាលនិងផ្សព្វផ្សាយប្រមាណ៩០% មានការយល់ដឹងពីអត្ថប្រយោជន៍នៃការអភិរក្សជលផលនិងមានការចូលរួមក្នុងសកម្មភាពនេះ ។

សកម្មភាពអភិរក្សបានតម្រង់ទិសទៅលើការបង្កើតនិងគ្រប់គ្រងកន្លែងអភិរក្សជលផល ដើម្បីរួមចំណែកធានាបាននូវផលស្តុកត្រីធម្មជាតិនិងសកម្មភាពនេសាទប្រកបដោយនិរន្តរភាព។ សកម្មភាពសំខាន់ៗរួមមានការបោះបង្គោលកំណត់ព្រំប្រទល់ ការរៀបចំកន្លែងយាមល្បាត ការបង្កើតក្រុមល្បាត ការពង្រឹងសមត្ថភាព ការបង្កើនការយល់ដឹងជាសាធារណៈ និងការតាមដានវាយតម្លៃ។

សហការជាមួយខណ្ឌរដ្ឋបាលជលផលនិងអង្គការដៃគូផ្សេងៗ បានបោះបង្គោលព្រំការពារកន្លែងអភិរក្សជលផលថ្មីចំនួន៣២បង្គោលនិងផែល្បាតចំនួន៤ផែ (សរុបមកដល់បច្ចុប្បន្នចំនួន៦២បង្គោលនិងផែយាមល្បាតចំនួន៣៤កន្លែង) ទម្លាក់ប្រអប់ថ្មជាង៥០០ប្រអប់ ដាក់កម្លាំងចម្រុះយាមជាប្រចាំនៅកន្លែងអភិរក្ស អភិរក្សថ្កាថ្ម ស្មៅសមុទ្រចំនួន៣.៨៣១ហិកតានៅតាមតំបន់ឆ្នេរ ដាំព្រៃលិចទឹកនិងព្រៃកោងកាងបានចំនួនជាង២.២០០ហិកតា និងការពារប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ជាច្រើនប្រភេទដូចជាកន្ធាយក្បាលកង្កែប ផ្សោតទឹកសាប ល្មិចក្រាស់ អណ្តើកសរសៃ សេះសមុទ្រ ក្រពើត្រី ត្រីនាគ ត្រីគល់រាំង និងត្រីរាជ។ល។ ដែលធ្វើឲ្យចំនួនរបស់វាកើនក្នុងចន្លោះពី១០ ទៅ៣០%។

| ទីតាំងកន្លែងអភិរក្ស | ចំនួន | ទំហំ (ហ.ត) |
|---|---|---|
| បឹងទន្លេសាប (ថ្មី) | ២៣ | ៩៣.២៤៦,០០ |
| បឹងទន្លេសាប(ចាស់) | ៨ | ២២.៥០០,០០ |
| មេគង្គក្រោម | ២៧ | ៤.២៥៧,០០ |
| មេគង្គលើ | ៤៦ | ៤.៣៥៥,៥០ |
| តំបន់ឆ្នេរ | ៤៤ | ៩១.៥២៣,៨៧ |
| សរុប | ១៤៨ | ២១៥ ៨៨២,៣៧ |



ក្រៅពីកន្លែងអភិរក្សទាំងនេះ នៅតាមសហគមន៍នេសាទមានរៀបចំអភិរក្សរបស់សហគមន៍នេសាទចំនួន៣៨២កន្លែង ស្មើ៦០៤៧៣ហិកតា ទៀតផងដែរ។ ក្រោយពីកំណែទម្រង់វិស័យជលផល រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យស្តីពី **ការបង្កើតទិវាមច្ឆជាតិ** ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ក្នុងគោលបំណងបំផុសប្រជាពលរដ្ឋឱ្យចូលរួមចំណែកការពារ អភិរក្ស និងអភិវឌ្ឍវិស័យជលផល ក្នុងទិសដៅធានា និរន្តរភាពនៃធនធានជលផលដើម្បីផលប្រយោជន៍សេដ្ឋកិច្ច សង្គម និងបរិស្ថាន។ ទិវាមច្ឆជាតិ លើកដំបូងត្រូវបានប្រារព្ធសាកល្បងនៅឆ្នាំ២០០២។ ពិធីនេះត្រូវបានបន្តប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំនិងបានប្រារព្ធចំនួន១២លើកមកហើយ។ រាល់លើកនៃពិធីទិវាមច្ឆជាតិ យើងតែងតែទទួលបាននូវអនុសាសន៍ដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ដែលជាត្រីវិស័យ ដើម្បីអភិវឌ្ឍវិស័យជលផលប្រកបដោយជោគជ័យ។ ម៉្យាងវិញទៀត ទិវាមច្ឆជាតិមិនត្រឹមតែប្រារព្ធ ធ្វើឡើងនៅថ្នាក់ជាតិប៉ុណ្ណោះទេ ថែមទាំងប្រារព្ធធ្វើនៅថ្នាក់ក្រោមជាតិទៀតផង។ កន្លងទៅរដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសហការជាមួយស្ថាប័ននានា អង្គការ និងដៃគូអភិវឌ្ឍបានលែងកូនត្រីក្នុងស្រុកដូចជាកូនត្រីឆ្ពិន ត្រីព្រលូង ត្រីអណ្តែង ត្រីកាហែ ត្រីកន្ធរ ត្រីប្រា ត្រីគល់រាំង កូនបង្កង និងវារីសត្វផ្សេងៗ ទៀតដូចជា កង្កែប អណ្តើក កន្ធាយទៅ ក្នុងទន្លេ បឹងនានា ដើម្បីបង្កើនផលស្តុកនៅក្នុងធម្មជាតិឲ្យកាន់តែសម្បូរច្រើនឡើងថែមទៀត។ ក្រាហ្វិកខាងក្រោមបង្ហាញពីស្ថិតិកូនត្រី កូនបង្កង និងវារីសត្វដែលបានលែងនៅក្នុងទិវាមច្ឆជាតិ ថ្នាក់ជាតិនិងក្រោមជាតិទៅក្នុងធម្មជាតិ(ឯកតាពាន់ក្បាល)។



### - មន្ត្រីនគរបាលយុត្តិធម៌

មកទល់នឹងបច្ចុប្បន្ននេះ មន្ត្រីជលផលដែលធ្វើសច្ចាប្រណិធានដើម្បីទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ចំនួន៣លើក(ឆ្នាំ២០០៨ ២០១០ និងឆ្នាំ២០១៣)មានចំនួនសរុប៥៣២នាក់។

### - ការកសាងបទដ្ឋានគតិយុត្ត

ក្រោយពីច្បាប់ស្តីពីជលផលត្រូវបានអនុម័តដាក់ឱ្យប្រើប្រាស់នាឆ្នាំ២០០៦ ក្នុងនេះបានចង្អុលបង្ហាញពីការត្រូវរៀបចំនូវឯកសារក្រោមច្បាប់នានាដូចជាអនុក្រឹត្យ ប្រកាស សេចក្តីសម្រេច... ដើម្បីជួយបំពេញបន្ថែមដល់ការអនុវត្តឱ្យកាន់តែមានភាពរលូន។ បទដ្ឋានគតិយុត្តរួមមាន៖

- អនុក្រឹត្យចំនួន១៤ច្បាប់
- ប្រកាសចំនួន២១ច្បាប់
- ប្រកាសរួមចំនួន០៧ច្បាប់
- បទបញ្ជាបច្ចេកទេសចំនួន០១ច្បាប់
- សេចក្តីជូនដំណឹង សេចក្តីណែនាំ និងសារាចរណែនាំចំនួន០៧ ច្បាប់

ជាមួយគ្នានេះដែរ បាននឹងកំពុងរៀបចំសេចក្តីព្រាងមួយចំនួនទៀតរួមមានច្បាប់ចំនួន០១ អនុក្រឹត្យចំនួន១៤ ប្រកាសចំនួន១៦ និងប្រកាសអន្តរក្រសួងចំនួន០៤។

### - ការងារទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល

តាមបទបញ្ជាដ៏មោះមុតរបស់រាជរដ្ឋាភិបាលនិងអនុសាសន៍ដ៏ថ្លៃថ្លារបស់ថ្នាក់ដឹកនាំកំពូលក្រោមកិច្ចសហការដ៏ល្អប្រសើរនិងទាន់ពេលវេលាពីស្ថាប័នពាក់ព័ន្ធធ្វើឲ្យយើងអាចការពារធនធានជលផលបានល្អប្រសើរដូចមានលទ្ធផលខាងក្រោម៖





លទ្ធផលបង្ក្រាបបទល្មើសជលផលពីឆ្នាំ២០០៣ ដល់ឆ្នាំ២០១៣




- **ការផ្សព្វផ្សាយបទដ្ឋានគតិយុត្ត**

ការផ្តល់ចំណេះដឹងនិងព័ត៌មានពាក់ព័ន្ធនឹងបទដ្ឋានគតិយុត្តដល់អាជ្ញាធរពាក់ព័ន្ធក៏ដូចជាប្រជាពលរដ្ឋនៅមូលដ្ឋានពិតជាជួយឱ្យមានការកាត់បន្ថយបទល្មើសនេសាទនិងមានការចូលរួមយ៉ាងសកម្មក្នុងការការពារធនធានជលផលដែលនេះជាភារកិច្ចដ៏ចាំបាច់សម្រាប់រដ្ឋបាលជលផលអនុវត្តនិងទទួលបានលទ្ធផលដូចតារាងខាងក្រោម៖

| ឆ្នាំ | ចំនួនវគ្គផ្សព្វផ្សាយ/បណ្តុះបណ្តាល | ចំនួនអ្នកចូលរួម (នាក់) |
|---|---|---|
| ២០០៦ | ២ | ១៧០ |
| ២០០៧ | ៩ | ៦១៨ |
| ២០០៨ | ៥២ | ៤.០៨៤ |
| ២០០៩ | ៤៣ | ២.៤១៨ |
| ២០១០ | ១៤៣ | ៨.៧៧៩ |
| ២០១១ | ១២២ | ១២.៥៤៣ |
| ២០១២ | ៧៣១ | ៤០.០៦២ |
| ២០១៣ | ២៩៨ | ២៥.២៥៩ |





## ការកែលម្អដែននេសាទនិងការការពារព្រៃលិចទឹក

### - ការកែលម្អដែននេសាទក្នុងអតីតឡូត៍នេសាទ:

បោះបង្គោលព្រំប្រទល់អតីតឡូត៍នេសាទចំនួន៨៩៣បង្គោល បង្គោលកញ្ចមអតីតឡូត៍នេសាទចំនួន៤៨បង្គោល ស្ពារព្រែកគោករីងរាក់ចំនួន១០៦.៦៥០ម៉ែត្រ បោះផ្ទាំងរូបភាពបញ្ឈប់ការឈូសឆាយនិងកាប់ព្រៃលិចទឹកចំនួន៩៧ផ្ទាំង និងដាក់លូស៊ីម៉ង់ត៍បានចំនួន២.០១៨លូ។

### - ការការពារព្រៃលិចទឹក:

ព្រៃលិចទឹកនៅក្នុងដែននេសាទទឹកសាបមាននៅក្នុងខេត្តចំនួន១២រួមមានខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម កណ្តាល តាកែវ ព្រៃវែង ក្រចេះ និងខេត្តស្ទឹងត្រែងមានទំហំសរុបប្រមាណជិត១លានហិកតា និងនៅតំបន់ឆ្នេរ (ព្រៃកោងកាង) ក្នុងខេត្តកែប កំពត ព្រះសីហនុ និងខេត្តកោះកុងមានទំហំប្រមាណ ៦៧.០០០ហិកតា ក្នុងនោះដែននេសាទទឹកសាបនៅខេត្តជុំវិញបឹងទន្លេសាបបានកំណត់ព្រំប្រទល់និងរៀបចំផែនទីដើម្បីការពារចំនួន៦៤៧.៤០៦ហិកតា(អនុក្រឹត្យលេខ១៩៧ អនក្រ. បក.ចុះថ្ងៃទី២៩ ខែ សីហា ឆ្នាំ២០១១) និងព្រៃកោងកាងនៅខេត្តកែប និងកំពតបានកំណត់ព្រំប្រទល់និងរៀបចំផែនទីដើម្បីការពារចំនួន២.៩៧១ហិកតា និងបោះបង្គោលព្រំប្រទល់ការពារព្រៃលិចទឹកចំនួន៦.៨០៦បង្គោល ។

### - ការងារផ្សព្វផ្សាយ:

ចុះផ្សព្វផ្សាយអំពីប្រកាសស្តីពីការកំណត់ប្រភេទឧបករណ៍នេសាទដែលអនុញ្ញាតឲ្យធ្វើនេសាទជាលក្ខណៈគ្រួសារ អនុក្រឹត្យស្តីពីការរំសាយឡូត៍នេសាទ អនុសាសន៍ទាំង៧ចំណុចរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសារៈសំខាន់ព្រៃលិចទឹកចំនួន២៩៨ វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន១៧.៤៤០នាក់(ប្រមាណជាង៥០% ជាស្ត្រី)។






# សកម្មភាពការងារនិងសមិទ្ធផលផ្នែកកែច្នៃជលផល

រដ្ឋបាលជលផលដែលមាននាយកដ្ឋានបច្ចេកវិទ្យាកែច្នៃនិងគុណភាព ជាសេនាធិការបាននិងកំពុងខិតខំធ្វើការសិក្សាស្រាវជ្រាវ តាមដាន និងត្រួតពិនិត្យសុវត្ថិភាពគុណភាពលើផល ផលិតផលជលផល ព្រមទាំងលើកកម្ពស់ការផ្តល់សេវាកម្មឲ្យកាន់តែប្រសើរឡើង ដើម្បីការពារសុខភាពសាធារណៈនិងជំរុញការនាំចេញផល ផលិតផលជលផលរបស់កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ។ រដ្ឋបាលជលផលបានសម្រេចលទ្ធផលការងារគួរឲ្យមោទនៈដូចខាងក្រោម៖

- ការសិក្សាស្រាវជ្រាវវាយតម្លៃហានីភ័យដែលកើតចេញពីការលើកដាក់ការកែច្នៃ ដឹកជញ្ជូននិងការថែរក្សាផលផលិត ផលជលផលព្រមទាំងសិក្សាទីផ្សារជលផលសម្រាប់ជំរុញការនាំចេញ។
- បានសហការសិក្សាស្រាវជ្រាវនិងតាមដានលើការចម្លងជីវពុល(Biotoxins) ក្នុងសិប្បីសត្វដែលស្ថិតនៅក្នុងក្របខណ្ឌនៃការតាមដានលើការចម្លងជីវពុលនៅក្នុងតំបន់អាស៊ាន។
- សេចក្តីព្រាងស្តង់ដារផលិតផលចំនួន៣គឺស្តង់ដារប្រហុក ស្តង់ដារត្រីងៀតរ៉ស់-ឆ្តោ និងស្តង់-ដារបង្គាបង្កករហ៊ស។
- ប្រកាសស្តីពីការដាក់ឲ្យប្រើប្រាស់គំរូ ទម្រង់ និងបែបបទនៃវិញ្ញាបនបត្រសុខភាពសម្រាប់បញ្ជាក់សុវត្ថិភាពគុណភាព។
- សេចក្តីព្រាងគោលការណ៍បច្ចេកទេសស្តីពីការអនុវត្តអនាម័យល្អ(GHP)គោលការណ៍បច្ចេកទេសស្តីពីអនុវត្តការផលិតល្អ(GMP)គោលការណ៍បច្ចេកទេសស្តីពីការវិភាគគ្រោះថ្នាក់និងចំណុចត្រួតពិនិត្យសំខាន់ៗ(HACCP)។
- នីតិវិធីសម្រាប់បញ្ជាក់គុណភាពផលិតផលជលផល(តែមគុណភាព)។
- សេចក្តីព្រាងស្តីពីប្រព័ន្ធត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពអាហារសម្រាប់ផល ផលិតផលជលផល
- បាននិងកំពុងកសាងមន្ទីរពិសោធន៍សម្រាប់វិភាគមីក្រូជីវសាស្ត្រដើម្បីបម្រើដល់ការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃសុវត្ថិភាព គុណភាពលើផល ផលិតផលជលផល។
- ការបង្កើតសមាគមនិងបណ្តុះបណ្តាលផ្សព្វផ្សាយដែលក្នុងនោះបានសម្រេចសកម្មភាពការងារសំខាន់ៗមួយចំនួនដូចជា៖ ការរៀបចំសមាគមអ្នកកែច្នៃផលិតផលជលផលចំនួន ១៦សមាគមនិងបានកសាងសមត្ថភាពតាមរយៈវគ្គបណ្តាលសម្រាប់គ្រូបង្គោលដែលមានមន្ត្រីថ្នាក់កណ្តាលនិងខណ្ឌជលផលចូលរួម បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការអនាម័យបច្ចេកទេសកែច្នៃនិងថែរក្សាផល ផលិតផលជលផលដល់សមាគមកែច្នៃនិងអ្នកនេសាទ

ព្រមទាំងបានផ្សព្វផ្សាយសៀវភៅណែនាំស្តីពីការអនុវត្តអនាម័យល្អសម្រាប់ទូកនេសាទនិងផែត្រីដល់សមាគមកែច្នៃជលផល។

- ការផ្តល់សេវាកម្មសាធារណៈ ការសម្របសម្រួល និងជំរុញការនាំចេញផល ផលិតផលជលផលរបស់កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិមួយ ចំនួនដូចជា ប្រទេសចិន កូរ៉េ ជប៉ុន វៀតណាម និងថៃ តាមរយៈការធ្វើឲ្យប្រសើរឡើងនូវគុណភាពនៃការផ្តល់សេវាកម្មបញ្ជាក់គុណភាព និងការផ្តល់ព័ត៌មានស្តីពីទីផ្សារសម្រាប់វិស័យឯកជន។
- ការងារត្រួតពិនិត្យសុវត្ថិភាព គុណភាពលើផល ផលិតផលជលផល បានចុះទៅត្រួតពិនិត្យនៅខេត្តមួយចំនួនរួមមានកណ្តាល តាកែវ កែប កំពត ព្រះសីហនុនិងកោះកុង ព្រមទាំងបានអប់រំនិងណែនាំដល់ពាណិជ្ជករមួយចំនួនឲ្យអនុវត្តតាមច្បាប់ស្តីពីជលផល និងលិខិតលេខ ៣១៨៤ កសក របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីសំណើចាត់វិធានការត្រួតពិនិត្យលើការបង្ក្រាបបទល្មើសនៃការដឹកជញ្ជូន និងការចិញ្ចឹមត្រីឆ្តោ និងត្រីរ៉ស់ និងការត្រួតពិនិត្យផល ផលិតផលជលផលនាំចូលឲ្យមានប្រសិទ្ធភាពខ្ពស់។





## ការសិក្សាស្រាវជ្រាវ

### វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលទឹកសាប



វិទ្យាស្ថានស្រាវជ្រាវនេះជាជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលដាណឺម៉ាកត្រូវបានដាក់សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការណ៍នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាតេជោ **ហ៊ុន សែន**។ វិទ្យាស្ថានបានសម្រេចសមិទ្ធផលជាច្រើនដូចជា៖

- ការប្រមូលគំរូត្រីដើម្បីសិក្សាស្រាវជ្រាវកំណត់អត្តសញ្ញាណ
- សិក្សាស្រាវជ្រាវពីផលស្តុកត្រីនិងតម្លៃផលនេសាទចាប់បាននៅក្នុងតំបន់បឹងទន្លេសាប
- សិក្សាស្រាវជ្រាវពីបរិមាណលំហូរកូនត្រីម្សៅដែលអណ្តែតពីទន្លេមេគង្គចូលទន្លេសាប
- សិក្សាស្រាវជ្រាវពីផលចាប់របស់ដាយត្រីតាមដងទន្លេសាប
- សិក្សាតាមដានផលនេសាទប្រចាំថ្ងៃរបស់អ្នកនេសាទលក្ខណៈគ្រួសារទូទាំងប្រទេស
- សិក្សាស្រាវជ្រាវនិងអភិរក្សប្រភេទវារីសត្វនៅអាងទន្លេមេគង្គ
- សិក្សាស្រាវជ្រាវពីអេកូឡូស៊ី តម្លៃ និងការផ្លាស់ទីរបស់ត្រី
- សិក្សាស្រាវជ្រាវពីឧបករណ៍នេសាទលបឡុក
- សិក្សាស្រាវជ្រាវពីផលប៉ះពាល់គម្រោងវារីអគ្គីសនីតាមដងទន្លេមេគង្គ ដើម្បីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា
- សិក្សាស្រាវជ្រាវពីបុរេសមិទ្ធលទ្ធភាពសាងសង់ជណ្តើរត្រីនៅទំនប់វារីអគ្គិសនីសេសានក្រោម២។

## មជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍវារីវប្បកម្មសមុទ្រ

មជ្ឈមណ្ឌលនេះជាជំនួយឥតសំណងនៃរាជរដ្ឋាភិបាលជប៉ុនដែលត្រូវបានសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការណ៍នាថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៣។ នៅក្នុងរយៈជាង១ឆ្នាំមជ្ឈមណ្ឌលសម្រេចបានសមិទ្ធផល៖



- សិក្សាសាកល្បងចិញ្ចឹមនិងថែរក្សាចំណីរស់
- សិក្សាសាកល្បងភ្ញាស់ចំណីរស់ ( Artermia )
- សិក្សាស្រាវជ្រាវផ្សំចំណីនិងថែបំប៉នមេពូជ
- សិក្សាសាកល្បងភ្ញាស់កូនត្រីឆ្តង់
- សិក្សាសាកល្បងភ្ញាស់-បង្កាត់បង្កង។



## មជ្ឈមណ្ឌលផលិតត្រីពូជបាទី



- សិក្សាស្រាវជ្រាវផលិតកូនត្រីនិងកូនបង្កងពូជ
- សិក្សាស្រាវជ្រាវគុណភាពត្រីមេពូជ
- សិក្សាស្រាវជ្រាវការភ្ញាស់-បង្កាត់ត្រីប្រា
- សិក្សាស្រាវជ្រាវពូជការប្រើប្រាស់និងផលិតចំណីត្រីនិងបង្កង
- ផ្សព្វផ្សាយនិងផ្តល់ចំណេះដឹងបច្ចេកទេសភ្ញាស់-បង្កាត់ត្រីនិងបង្កងដល់កសិករចិញ្ចឹម
- ចងក្រងផលិតឯកសារបច្ចេកទេស។

## វិទ្យាស្ថានជាតិស្រាវជ្រាវនិងអភិវឌ្ឍន៍វារីវប្បកម្មសម្តេចតេជោ ហ៊ុន សែន

វិទ្យាស្ថានជាតិនេះត្រូវបានសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការណ៍នាថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០១៤ ដើម្បីបំពេញតម្រូវការនិងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រតាមរយៈការជំរុញផលិតកម្មកូនត្រីពូជនិងសិក្សាស្រាវជ្រាវបង្កាត់-ភ្ញាស់ពូជ ត្រីនិងចិញ្ចឹមត្រីយកសាច់ ដើម្បីឲ្យផលិតផលចិញ្ចឹមមានគុណភាពខ្ពស់។ ក្រៅពីត្រីវិទ្យាស្ថានមានផ្នែកផលិតកូនបង្កងពូជ ថៃបំប៉ននិងចិញ្ចឹមបង្កងយកសាច់ នៅក្នុងស្រះនិងស៊ីង ជាមួយគ្នា នេះដែរ វិទ្យាស្ថានមានម៉ាស៊ីនផលិតចំណីត្រីនិងបង្កងថែមទៀត។



## កិច្ចសហប្រតិបត្តិជាមួយកម្មវិធីនិងគម្រោងនានា

បច្ចុប្បន្ននេះ យើងបាននឹងកំពុងសហការជាមួយកម្មវិធីនិងគម្រោងនានា ដែលអនុវត្តក្នុងរយៈពេលខ្លី មធ្យម និងវែងដោយជួយអភិវឌ្ឍអនុវិស័យសំខាន់ៗដូចជា វារីវប្បកម្ម សហគមន៍នេសាទ ការការពារធនធានជលផលកំពុងរងគ្រោះថ្នាក់ ការកែច្នៃនិងគុណភាព។ល។ដែលកម្មវិធី គម្រោង សកវិទ្យាល័យនិងវិទ្យាស្ថានដូចខាងក្រោម៖

- ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)
- គណៈកម្មការទន្លេមេគង្គ (MRC)
- អង្គការស្បៀងអាហារនិងកសិកម្មនៃសហប្រជាជាតិ (FAO)

- សហភាពអឺរ៉ុប (EU)
- អង្គការមជ្ឈមណ្ឌលត្រីពិភពលោក (WorldFish Centre)
- អង្គការសង្គមអភិរក្សសត្វព្រៃ (WCS)
- អង្គការអភិរក្សអន្តរជាតិ (CI)
- អង្គការមូលនិធិសត្វព្រៃពិភពលោក (WWF)
- អង្គការសត្វព្រៃនិងរុក្ខជាតិអន្តរជាតិ (FFI)
- អង្គការទស្សនៈពិភពលោក (World Vision)
- អង្គការអុកស្វាមអូស្ត្រាលី (Oxfam Australia)
- អង្គការធនាគារពិភពលោក (WB)
- អង្គការរៀបចំអភិវឌ្ឍឧស្សាហកម្មនៃសហប្រជាជាតិ (UNIDO)
- អង្គការ (INFOFISH)
- ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់កិច្ចអភិវឌ្ឍអន្តរជាតិ (USAID)
- កម្មវិធីរេដ៍បូក(REDD+)
- មជ្ឈមណ្ឌលអភិវឌ្ឍន៍វិស័យជលផលនៅតំបន់អាស៊ីអាគ្នេយ៍ (SEAFDEC)គម្រោង SEAFDEC-Sweden
- អង្គការបណ្តាញមជ្ឈមណ្ឌលវារីវប្បកម្មក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិច(NACA)
- សកលវិទ្យាល័យកូភេនហាហ្គិននៃប្រទេសដាណឺម៉ាក
- សកលវិទ្យាល័យម៉ាហ៊ីដុលនៃប្រទេសថៃ
- វិទ្យាស្ថានអាហារូបត្ថម្ភនៃប្រទេសវៀតណាម
- វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍នៃប្រទេសបារាំង
- អង្គការ DANIDA
- អង្គការ WFP
- អង្គការ RACHA
- អង្គការ HKI

## ការបោះពុម្ពផ្សព្វផ្សាយ

កិច្ចការដ៏សំខាន់មួយទៀតដែលជួយឱ្យរដ្ឋបាលជលផលសម្រេចបានជោគជ័យលើបេសកកម្មរបស់ខ្លួននោះ គឺការរៀបចំចងក្រងបោះពុម្ព ឯកសារនានា ដែលខ្លួនបានអនុវត្តនិងសិក្សាស្រាវ-ជ្រាវកន្លងមកក្នុងគោលបំណងដើម្បីផ្សព្វផ្សាយនូវព័ត៌មាននិងផ្តល់នូវចំណេះដឹងដល់អ្នកពាក់-ព័ន្ធទាំងអស់ ដែលជាតម្រូវការមានដូចជាបទដ្ឋានគតិយុត្ត(ច្បាប់ស្តីពីជលផល អនុក្រឹត្យស្តីពី ការគ្រប់គ្រងសហគមន៍នេសាទ...)ឯកសារគោលនយោបាយ ផែនការយុទ្ធសាស្ត្រ(ក្របខណ្ឌផែនការយុទ្ធសាស្ត្រ...) ឯកសារវិទ្យាសាស្ត្រពាក់ព័ន្ធការនេសាទ (ឧបករណ៍នេសាទ ចំណាត់ថ្នាក់ប្រភេទត្រី...)ឯកសារបច្ចេកទេសពាក់ព័ន្ធវារីវប្បកម្ម(បច្ចេកទេសចិញ្ចឹមត្រី ចិញ្ចឹមបង្កង...) ឯកសារបច្ចេកទេសពាក់ព័ន្ធ ការកែច្នៃនិងគុណភាព(ការណែនាំស្តីពីការអនុវត្តអនាម័យល្អ...) ឯកសារបណ្តុះ បណ្តាលនិងផ្សព្វផ្សាយ (កូនសៀវភៅ ខិត្តបណ្ណ ផ្ទាំងរូបភាពត្រីទឹកសាប ត្រីសមុទ្រប្រភេទកំពុងរងគ្រោះថ្នាក់...) ទស្សនាវដ្តីជលផល ទិនានុលេខន៍ប្រចាំឆ្នាំ និងផ្ទាំងប៉ាណូបង្ហាញនានា(ការគ្រប់គ្រងធនធានជលផល)ដែលមានចំនួនសរុបរាប់ម៉ឺនច្បាប់។























## សន្និដ្ឋាន

ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាតេជោ **ហ៊ុន សែន** ដែលតែងតែផ្តល់នូវអនុសាសន៍ដ៏ថ្លៃថ្លាសម្រាប់ជាប្រទីបបំភ្លឺផ្លូវធ្វើឱ្យការគ្រប់គ្រងនិងអភិវឌ្ឍន៍វិស័យជលផល រយៈពេលកន្លងមកនេះមានការប្រែប្រួលរីកចម្រើនគួរឲ្យកត់សម្គាល់ដែលជាលទ្ធផលសំខាន់ រួមមាន៖

- ការសាងសង់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍជលផលទឹកសាប
- ការសាងសង់វិទ្យាស្ថានជាតិស្រាវជ្រាវនិងអភិវឌ្ឍវារីវប្បកម្មសម្តេចតេជោ **ហ៊ុន សែន**
- ការសាងសង់មជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍវារីវប្បកម្មសមុទ្រ
- ការសាងសង់មជ្ឈមណ្ឌលស្រាវជ្រាវនេសាទបឹងទន្លេសាប
- ការសាងសង់និងអភិវឌ្ឍមជ្ឈមណ្ឌលផលិតត្រីពូជបាទី
- ការរៀបចំបង្កើតវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍជលផលសមុទ្រ
- ការជំរុញការស្រាវជ្រាវនិងអភិវឌ្ឍវារីវប្បកម្មដែលឈានដល់ការភ្ញាស់កូនត្រីប្រា កូនត្រីឆ្តង់ និង កូនបង្កងបានទទួលជោគជ័យជាប្រវត្តិសាស្ត្រ
- ការជំរុញសកម្មភាពបង្ក្រាបបទល្មើសជលផលដោយអនុវត្តតាមស្មារតីបទបញ្ជាលេខ០១បប របស់រាជរដ្ឋាភិបាលតាមអនុសាសន៍ដ៏ថ្លៃថ្លារបស់សម្តេចតេជោ **ហ៊ុន សែន**
- ការចាត់វិធានការអភិរក្សធនធានជលផលរួមមានទាំងផ្កាថ្ម ស្មៅសមុទ្រ ព្រៃលិចទឹកនិងព្រៃកោង កាងជាដើម ដើម្បីឈានទៅបង្កើតឧទ្យានអភិរក្សជលផលសមុទ្រ
- ការរៀបចំក្របខណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យជលផល១០ឆ្នាំ(២០១០-២០១៩)
- ការបោះពុម្ពផ្សាយសៀវភៅបច្ចេកទេស ប៉ាណូ ប៉ូស្ទ័របានជាច្រើនម៉ឺនច្បាប់...។





ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
រដ្ឋបាលជលផល

# រចនាសម្ព័ន្ធរបស់រដ្ឋបាលជលផល (រជផ.)

**នា.កិច្ចការរដ្ឋបាល និងនីតិកម្ម**
- ការិ.រដ្ឋបាលនិងផ្គត់ផ្គង់
- ការិ.បុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស
- ការិ.នីតិកម្ម
- ការិ.វិវាទកម្ម

**នា.ផែនការ ហិរញ្ញវត្ថុ និងសហប្រតិបត្តិការអន្តរជាតិ**
- ការិ.រដ្ឋបាលនិងផែនការ
- ការិ.សហប្រតិបត្តិការអន្តរជាតិនិងស្ថិតិ
- ការិ.គណនេយ្យនិងហិរញ្ញវត្ថុ
- ការិ.តាមដាននិងវាយតម្លៃ

**នា.អភិវឌ្ឍន៍វារីវប្បកម្ម**
- ការិ.រដ្ឋបាលនិងផ្សព្វផ្សាយ
- ការិ.វារីវប្បកម្មទឹកសាប
- ការិ.វារីវប្បកម្មសមុទ្រ
- ការិ.ស្រះជម្រកត្រីសហគមន៍

**នា.កិច្ចការជលផល**
- ការិ.រដ្ឋបាល
- ការិ.នេសាទទឹកសាប
- ការិ.នេសាទសមុទ្រ
- ការិ.ដែននេសាទ ផែនទី និងព័ត៌មានភូមិសាស្ត្រ

**នា.អភិវឌ្ឍន៍សហគមន៍នេសាទ**
- ការិ.រដ្ឋបាលនិងតាមដានការអនុវត្តន៍
- ការិ.សហគមន៍នេសាទ
- ការិ.អភិវឌ្ឍន៍ជីវភាពសហគមន៍នេសាទ
- ការិ.បណ្តុះបណ្តាលនិងផ្សព្វផ្សាយ

**នា.បច្ចេកវិទ្យាកែច្នៃ និងគុណភាព**
- ការិ.រដ្ឋបាល បណ្តុះបណ្តាល និងផ្សព្វផ្សាយ
- ការិ.ត្រួតពិនិត្យគុណភាព និងសុវត្ថិភាព
- ការិ.ស្រាវជ្រាវនិងអភិវឌ្ឍន៍ និងបច្ចេកវិទ្យា
- ការិ.សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ

**នា.អភិរក្សជលផល**
- ការិ.រដ្ឋបាល បណ្តុះបណ្តាល និងផ្សព្វផ្សាយ
- ការិ.អភិរក្សជលផល
- ការិ.វារិជាតកំពុងរងគ្រោះថ្នាក់
- ការិ.អភិរក្សនិងអភិវឌ្ឍន៍ឧស្សាហកម្មក្រពើ
- ការិ.អភិរក្សនិងអភិវឌ្ឍន៍សត្វផ្សោត

**វិ.ស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលទឹកសាប**
- ការិ.រដ្ឋបាល
- ការិ.ជីវសាស្ត្រ
- ការិ.ស្រាវជ្រាវបច្ចេកវិទ្យាជលផល
- ការិ.សេដ្ឋកិច្ចសង្គម
- មន្ទីរពិសោធន៍

**វិ.ស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រ**
- ការិ.រដ្ឋបាល
- ការិ.ជីវសាស្ត្រ
- ការិ.ស្រាវជ្រាវបច្ចេកវិទ្យាជលផល
- ការិ.សេដ្ឋកិច្ចសង្គម
- មន្ទីរពិសោធន៍

**វិ.ជាតិស្រាវជ្រាវនិងអភិវឌ្ឍន៍វារីវប្បកម្ម សម្តេច ហ៊ុន សែន**
- ការិ.រដ្ឋបាលនិងផែនការគណនេយ្យ
- ការិ.ស្រាវជ្រាវនិងពិសោធន៍
- ការិ.ផលិតកម្មនិងវារីវប្បកម្ម
- ការិ.បណ្តុះបណ្តាលផ្សព្វផ្សាយ និងកិច្ចសហប្រតិបត្តិការ

**អធិការដ្ឋានរដ្ឋបាលជលផលចតុមុខ**
- ខណ្ឌរជផ.ភ្នំពេញ
- ខណ្ឌរជផ.កណ្តាល
- ខណ្ឌរជផ.ព្រៃវែង
- ខណ្ឌរជផ.ស្វាយរៀង
- ខណ្ឌរជផ.តាកែវ

**អធិការដ្ឋានរដ្ឋបាលជលផលមេគង្គ**
- ខណ្ឌរជផ.កំពង់ចាម
- ខណ្ឌរជផ.ក្រចេះ
- ខណ្ឌរជផ.ស្ទឹងត្រែង
- ខណ្ឌរជផ.រតនគីរី
- ខណ្ឌរជផ.មណ្ឌលគីរី
- ខណ្ឌរជផ.ត្បូងឃ្មុំ

**អធិការដ្ឋានរដ្ឋបាលជលផលខាងត្បូងបឹងទន្លេសាប**
- ខណ្ឌរជផ.បាត់ដំបង
- ខណ្ឌរជផ.កំពង់ឆ្នាំង
- ខណ្ឌរជផ.ពោធិ៍សាត់
- ខណ្ឌរជផ.កំពង់ស្ពឺ
- ខណ្ឌរជផ.ប៉ៃលិន

**អធិការដ្ឋានរដ្ឋបាលជលផលខាងជើងបឹងទន្លេសាប**
- ខណ្ឌរជផ.សៀមរាប
- ខណ្ឌរជផ.កំពង់ធំ
- ខណ្ឌរជផ.ព្រះវិហារ
- ខណ្ឌរជផ.បន្ទាយមានជ័យ
- ខណ្ឌរជផ.ឧត្តរមានជ័យ

**អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ**
- ខណ្ឌរជផ.កែប
- ខណ្ឌរជផ.កំពត
- ខណ្ឌរជផ.កំពង់សោម
- ខណ្ឌរជផ.កោះកុង

រដ្ឋបាលជលផលបែងចែកជា៖៥ អធិការដ្ឋាន :០៥ ខណ្ឌ :២៥ ផ្នែក :៤៨ និង សង្កាត់ : ១៥៨

KINGDOM OF CAMBODIA

Nation Religion King



# CAMBODIA FISHERIES AT A GLANCE





This publication is funded by the European Union

# Cambodian Fisheries At a Glance

The contents of this publication are the sole responsibility of Fisheries Administration and can in no way be taken to reflect the views of the European Union.



2014
Fisheries Administration,
# 186, Preah Norodom Blvd.,Sangkat Tonle Bassac, Khan Chamcar Mon,
Phnom Penh Capital City, Kingdom of Cambodia, P.O. Box 582.
Website:www.fia.gov.kh

# Foreword

Since ancient times, rice and fish have been integral staple foods of the daily diets of Cambodian people, and fish has been described as crucial and priceless. Because Cambodia's geography is dominated by the Mekong River, which is more than 500 kilometers in length, and the Tonle Sap Great Lake is its heart, the country is rich in natural resources of all kinds, especially fisheries.

Cambodia's fisheries play a very important role in contributing to employment opportunities to about 6 million people working full- and part-time in fisheries and fisheries related activities, providing people's livelihoods, national food security and adding approximately US$1.5 Billion per year to the economy, corresponding to around 8-12% of total Gross Domestic Product (GDP).

Today, about 500 inland fish species and 520 marine fish species are known in Cambodia, and the total annual freshwater and marine capture fisheries production is estimated at about 700-800 thousand tons, of which the annual yield of inland fish amounts to 500-600 thousand tons, ranking 4th worldwide in inland fish production after China, India and Bangladesh. The annual marine capture fish production is estimated at 100-150 thousand tons, and the annual aquaculture production adds some 90-100 thousand tons. Cambodian fish consumption is 63kg/person/year and fish provides 81.5% of Cambodian people's animal protein intake.

At present, multiple factors, including population growth, climate change, overfishing etc. are likely to have potential impacts on fisheries resources. Recently, the Royal Government of Cambodia under the wise leadership of Samdech Akka Moha Sena Padei Techo HUN SEN, had reformed the fisheries sector by abolishing all fishing lots and transferring the management to community people to conserve and use in a sustainable manner to contribute to poverty reduction.

Since the fisheries policy reform from 2000 to 2014 was adopted 14 years ago, the Fisheries Administration has worked tirelessly on the in-depth implementation of the policy reforms to achieve success and brilliant achievements, including aquaculture development, fishery management and community fisheries development, conservation of fishery resources, improving fisheries conservation and protected areas, protection of flooded and mangrove forests, development of community fish refuges, processing and quality control of fishery products, planning, and research and extension services.

**Prof. Nao Thuok, Ph.D.**
Delegate of the Royal Government of Cambodia,
Director General of Fisheries Administration

## Contents


Vision for the Fisheries Sector :........................................................ 1
Mission of the Fisheries Sector........................................................ 1
Mandate of the Fisheries Sector........................................................ 1
Fisheries Reform........................................................ 1
Fish Production (2000-2013)........................................................ 3
Aquaculture Development and Community Fish Refuges........................................................ 4
Community Fisheries Management........................................................ 5
Fisheries Conservation ........................................................ 7
Law Enforcement ........................................................ 9
Improvement of Fishery Domain and Protection of Flooded Forest........................................................ 11
Work Activities and Achievements of Post-harvest Fisheries........................................................ 12
Research Division........................................................ 13
Cooperation With Other Programs and Projects........................................................ 15
Publication........................................................ 17
Conclusions........................................................ 18
Organizational Chart of FiA ........................................................ 19

## Vision for the Fisheries Sector

